# Secure Access Washington (SAW)

ការណែនាំអំពីការចុះឈ្មោះ WSGC My Account

សេវាលើអ៊ីនធឺណិតសម្រាប់ WSGC (Washington State Gambling Commission, គណៈកម្មាធិការល្បែងស៊ីសងរដ្ឋ Washington) មានតែតាមរយៈ SAW (Secure Access Washington, សិទ្ធិចូលប្រើប្រាស់ប្រកបដោយសុវត្ថិភាពរបស់រដ្ឋ Washington) តែប៉ុណ្ណោះ។ SAW គឺជាគេហទំព័រដែលអាចឱ្យអ្នកប្រើប្រាស់ចូលប្រើប្រាស់សេវាសម្រាប់ទីភ្នាក់ងាររដ្ឋាភិបាលជាច្រើននៃរដ្ឋ Washington ដោយប្រើប្រាស់លេខសម្គាល់អ្នកប្រើប្រាស់ និងពាក្យសម្ងាត់តែមួយប៉ុណ្ណោះ។ ការណែនាំនេះនឹងណែនាំអ្នកអំពីការចុះឈ្មោះប្រើប្រាស់ SAW និងការបញ្ចូលសេវាលើអ៊ីនធឺណិតរបស់គណៈកម្មាធិការល្បែងស៊ីសង "WSGC My Account (WSGC គណនីរបស់ខ្ញុំ)"។

ប្រសិនបើអ្នកត្រូវការជំនួយពាក់ព័ន្ធនឹងការចុះឈ្មោះ សូមទាក់ទងទៅអ្នកឯកទេសផ្នែកផ្តល់អាជ្ញាបណ្ណតាមរយៈ (360) 486-3441 ឬ Licensing@wsgc.wa.gov។

**ការណែនាំ៖**

1. បើកកម្មវិធីរុករកលើអ៊ីនធឺណិតរបស់អ្នក រួចចូលទៅកាន់គេហទំព័រ secureaccess.wa.gov។
2. ចុចប៊ូតុង **SIGN UP! (ចុះឈ្មោះ!)**។



3. វាយបញ្ចូលព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក ព័ត៌មានទំនាក់ទំនង (ជាជម្រើស) និងបង្កើតឈ្មោះអ្នកប្រើប្រាស់ និងពាក្យសម្ងាត់។



4. ចុចប្រអប់ "**I'm not a robot (ខ្ញុំមិនមែនជាមនុស្សយន្ត)**"។

អ្នកនឹងឃើញផ្ទាំងសុវត្ថិភាព ហើយនឹងត្រូវបានស្នើសុំឱ្យជ្រើសរើសរូបភាពជាក់លាក់មួយចំនួន។
បន្ទាប់ពីអ្នកធ្វើការជ្រើសរើសរួច សូមចុចប៊ូតុង **VERIFY (ផ្ទៀងផ្ទាត់)**។ (ប្រសិនបើមិនមានរូបភាពត្រឹមត្រូវទេ សូមចុចប៊ូតុង **SKIP (រំលង)**)



5. ចុចប៊ូតុង **<u>SUBMIT</u> (ដាក់បញ្ជូន)**។



អ្នកនឹងទទួលបានការជូនដំណឹងថាតំណសម្រាប់បើកដំណើរការត្រូវបានផ្ញើទៅអ៊ីមែលរបស់អ្នក។




6. បិទវិនដូកម្មវិធីរុករកលើអ៊ីនធឺណិតទាំងឡាយដែលអ្នកបានបើក។

7. ចូលទៅប្រអប់ទទួលអ៊ីមែលរបស់អ្នក។
អ៊ីមែលសម្រាប់បើកដំណើរការនឹងត្រូវបានផ្ញើពីអាសយដ្ឋានអ៊ីមែលៈ
secureaccess@cts.wa.gov។ (ប្រសិនបើអ្នកមិនឃើញអ៊ីមែលនោះក្នុងប្រអប់សាររបស់អ្នកទេ
សូមពិនិត្យមើលក្នុងថតសារឥតបានការ។)



8. បើកអ៊ីមែលនោះ រួចចុចតំណសម្រាប់បើកដំណើរការ។



Wed 8/1/2018 5:17 PM

secureaccess@cts.wa.gov

SecureAccess Washington : Welcome to SecureAccess Washington

To Corrigan, Isabel (GMB)

We removed extra line breaks from this message.

You are almost finished, Isabel...

Thank you for signing up with Secure Access Washington.

Your username is: IsabelC@123

To activate your account please click: https://test-secureaccess.wa.gov/public/saw/pub/regConfirm.do?s=72062&userId=IsabelC%40123

For questions or concerns about your SecureAccess Washington account, please visit https://test-secureaccess.wa.gov/public/saw/pub/help.do

Thank you,
The Secure Access Washington Team

--------------------------

This is an automated message sent by the SecureAccess Washington CUSTOMER TEST environment. THIS IS NOT PRODUCTION.
Login at https://test-secureaccess.wa.gov If you require assistance, please leave us a note at https://test-secureaccess.wa.gov/public/saw/pub/help.do

9. ចុចប៊ូតុង **<u>LOGIN</u>** (**ចូលគណនី**)។




10. វាយបញ្ចូលឈ្មោះអ្នកប្រើប្រាស់ និងពាក្យសម្ងាត់ រួចចុច **<u>SUBMIT</u>** (**ដាក់បញ្ជូន**)។



11. ចុចប៊ូតុង **<u>ADD A NEW SERVICE</u> (បញ្ចូលសេវាថ្មី)**។




12. ចុចប៊ូតុង "**<u>I would like to browse a list of services by agency</u> (ខ្ញុំចង់ស្រាវរកបញ្ជីសេវាតាមរយៈទីភ្នាក់ងារ)**"។



13. ជ្រើសរើស **<u>Washington State Gambling Commission</u>** **(គណៈកម្មាធិការល្បែងស៊ីសងរដ្ឋ Washington)** ពីបញ្ជីទីភ្នាក់ងារ។




14. ចុចប៊ូតុង **<u>APPLY</u>** (**ដាក់ពាក្យ**)



**<u>ការផ្ទៀងផ្ទាត់អត្តសញ្ញាណ៖</u>**
ការបំពេញការផ្ទៀងផ្ទាត់អត្តសញ្ញាណនឹងអាចឱ្យអ្នកចូលប្រើប្រាស់គណនីរបស់អ្នកភ្លាមៗ។ SAW សួរសំណួរអ្នកពីព័ត៌មានដែលអ្នកបានដាក់បញ្ជូនទៅទីភ្នាក់ងាររដ្ឋផ្សេងៗ (ឧ. ក្រសួងផ្តល់អាជ្ញាបណ្ណ [Dept of Licensing], ក្រសួងសុខាភិបាល [Dept. of Health]។ អ្នកនឹងត្រូវបានសួរអំពីយានយន្តដែលអ្នកមាន មនុស្សដែលអ្នកស្គាល់ បទពិសោធវិជ្ជាជីវៈរបស់អ្នក។ល។

ប្រសិនបើអ្នកមិនដឹងចម្លើយចំពោះសំណួរទាំងនេះ អ្នកអាចនឹងស្នើសុំការអនុញ្ញាតរំលងជំហាននេះ។ ប៉ុន្តែ យើងអាចនឹងចំណាយពេល
2-7 ថ្ងៃនៃថ្ងៃធ្វើការក្នុងការផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់អ្នក។

15. វាយបញ្ចូលអាសយដ្ឋានផ្លូវផ្ទះរបស់អ្នក រួចចុចប៊ូតុង **<u>CONTINUE</u> (បន្ត)**។



16. ឆ្លើយសំណួរផ្ទៀងផ្ទាត់អត្តសញ្ញាណ សំណួរទាំងនេះផ្អែកលើកំណត់ត្រាសាធារណៈរបស់អ្នក ដូច្នេះឧទាហរណ៍ខាងក្រោមនឹងមានភាពខុសគ្នាពីសំណួរដែលអ្នកនឹងត្រូវបានសួរ។

17. ចុចប៊ូតុង **<u>CONTINUE</u> (បន្ត)** បន្ទាប់ពីសំណួរនីមួយៗ។






## **មិនអាចផ្ទៀងផ្ទាត់អត្តសញ្ញាណបានទេ៖**

ប្រសិនបើអ្នកមិនអាចឆ្លើយសំណួរផ្ទៀងផ្ទាត់អត្តសញ្ញាណបានត្រឹមត្រូវទេ សូមសាកល្បងជម្រើសមួយក្នុងបញ្ជីជម្រើស “What should I do next (តើខ្ញុំគួរធ្វើអ្វីបន្ទាប់?)"។ អ្នកអាចនឹងឆ្លើយសំណួរផ្ទៀងផ្ទាត់អត្តសញ្ញាណបានត្រឹមត្រូវ បន្ទាប់ពីកែកម្រែងព័ត៌មាន ឬអាសយដ្ឋានផ្ទះរបស់អ្នក។

A. ប្រសិនបើអ្នកនៅតែមិនអាចឆ្លើយសំណួរផ្ទៀងផ្ទាត់អត្តសញ្ញាណបានទេ សូមចុចតំណទំព័រ **Request permission to skip this step (ស្នើសុំការអនុញ្ញាតរំលងជំហាននេះ)**។




B. ចុចប៊ូតុង OK (យល់ព្រម)។



C. ចេញពីគណនី SAW។

D. បិទវិនដូកម្មវិធីរុករកលើអ៊ីនធឺណិតទាំងឡាយដែលបានបើក។

E. យើងនឹងផ្ញើអ៊ីមែលទៅអ្នកដោយមានសំណួរមួយចំនួនសម្រាប់ឱ្យអ្នកឆ្លើយអំពីខ្លួនអ្នក ឬសម្រាប់អង្គភាពរបស់អ្នក។

- ប្រសិនបើអ្នកមិនឆ្លើយតបទៅកាន់អ៊ីមែលនោះទេ យើងនឹងបោះបង់ចោលសំណើរបស់អ្នកបន្ទាប់ពីរយៈពេល 7 ថ្ងៃ។
- សូមពិនិត្យមើលថត "សារឥតបានការ" របស់អ្នក។ ជួនកាល អ៊ីមែលរបស់យើងចូលទៅក្នុងថតនោះ។
- បន្ទាប់ពីយើងពិនិត្យមើលចម្លើយក្នុងអ៊ីមែលរបស់អ្នក ហើយប្រសិនបើយើងយល់ព្រមលើសំណើរបស់អ្នក អ្នកនឹងទទួលបានអ៊ីមែលមួយទៀតពី secureaccess@cts.wa.gov ដែលមានចំណងជើងថា "KBABypass Approved! (បានយល់ព្រមការបញ្ចៀស KBA!)"

F. ចុចលើតំណទំព័រក្នុងអ៊ីមែល ដើម្បីចូលគណនី SAW។ អ្នកនឹងត្រូវបញ្ចូលសេវា WSGC My Account (WSGC គណនីរបស់ខ្ញុំ) ឡើងវិញ (ត្រឡប់ទៅជំហានទី 11 វិញសម្រាប់ការណែនាំ)។



18. **<u>ប្រសិនបើបច្ចុប្បន្ននេះអ្នកមានអាជ្ញាបណ្ណរួចហើយ៖</u>**
ស្វែងយកលេខ PIN (Personal Indentification Number, លេខសម្គាល់អត្តសញ្ញាណបុគ្គល) របស់អ្នក និងលេខអតិថិជនឬអាជ្ញាបណ្ណ។ អ្នកអាចស្វែងរកព័ត៌មាននោះក្នុងឯកសារទាំងនេះ។

- **<u>សម្រាប់បុគ្គលិកក្នុងបន្ទប់លេងបៀ អ្នកតំណាង ឬអ្នកគ្រប់គ្រងល្បែងស៊ីសង៖</u>**
  - អ៊ីមែលរំឭកឱ្យបន្តអាជ្ញាបណ្ណរបស់អ្នក


*This report displays the content in the email to licensee and not the actual email*
From: DoNotReply@wsgc.wa.gov
To: your_email @gmail.com
cc:
Subject: Gambling License Renewal Due

Client/License Number:
Pin:

- **<u>សម្រាប់អង្គភាព (អង្គភាពមិនរកប្រាក់ចំណូល និងអាជីវកម្មពាណិជ្ជកម្ម)៖</u>**
  - សំបុត្រ ការណែនាំ My Account (គណនីរបស់ខ្ញុំ)
  - អ៊ីមែលរំឭកឱ្យបំពេញរបាយការណ៍អាជ្ញាបណ្ណប្រចាំត្រីមាសរបស់អ្នក។
  - អ៊ីមែលរំឭកឱ្យបន្តអាជ្ញាបណ្ណរបស់អ្នក។


WASHINGTON STATE GAMBLING COMMISSION
Location: 4565 7th Avenue SE, Lacey WA 98503
Mailing Address: P.O. Box 42400, Olympia WA 98504-2400
Telephone: 360-486-3440 / Fax Number: 360-486-3631
In-State Toll-Free: 1-800-345-2529 / Web Site: www.wsgc.wa.gov

ANNUAL RENEWAL APPLICATION FOR NONPROFIT ORGANIZATION

WAC 230-05-128 requires you to submit your application and fees at least 15 days in advance of the license expiration date.

YOUR GAMBLING LICENSE(S) WILL EXPIRE ON December 31, 2020

Organization Number: 00-
Pin Number:

## 19. <u>ព័ត៌មានបន្ថែមសម្រាប់ WSGC៖</u>

**<u>ប្រសិនបើបច្ចុប្បន្ននេះអ្នកមានអាជ្ញាបណ្ណរួចហើយ៖</u>**

- អ្នកគ្រាន់តែត្រូវវាយបញ្ចូលលេខ PIN របស់អ្នក និងលេខអតិថិជន ឬលេខអាជ្ញាបណ្ណលើទំព័រនេះ។
- អ្នកអាចទុកសំណួរផ្សេងៗទៀតទាំងអស់ឱ្យនៅទទេបាន។

- ចុចប៊ូតុង **<u>SUBMIT</u> (ដាក់បញ្ជូន)** បន្ទាប់ពីវាយបញ្ចូលលេខទាំងនេះ។









**ព័ត៌មានបន្ថែមសម្រាប់ WSGC៖**

**ប្រសិនបើអ្នកមិនធ្លាប់ទទួលបានអាជ្ញាបណ្ណពីមុនទេ៖**

- បំពេញព័ត៌មានទាំងអស់ដែលពាក់ព័ន្ធនឹងអ្នក ឬអង្គភាពរបស់អ្នក។
- ប្រសិនបើអ្នកមិនដឹងថាឆ្លើយបែបណា អ្នកអាចទុកសំណួរឱ្យនៅទំនេបាន។
- អ្នកនឹងមិនមាន PIN ឬលេខអតិថិជនឬអាជ្ញាបណ្ណនោះទេ។ ទុកកន្លែងបញ្ចូលទាំងនោះឱ្យនៅទំនេ។

- ចុចប៊ូតុង **SUBMIT (ដាក់បញ្ជូន)** នៅពេលអ្នករួចរាល់។



**ការចុះឈ្មោះបានបញ្ចប់!**

20. ចុចប៊ូតុង **OK (យល់ព្រម)**។




21. ចុចប៊ូតុង **Access Now (ចូលប្រើប្រាស់ឥឡូវនេះ)**។




22. ចុចប៊ូតុង **CONTINUE (បន្ត)**។



**<u>ការផ្ទៀងផ្ទាត់ច្រើនកត្តា៖</u>**
ដើម្បីបង្ការការក្លែងបន្លំ និងការលួចអត្តសញ្ញាណ SAW តម្រូវឱ្យមានការផ្ទៀងផ្ទាត់បន្ថែមពីលើឈ្មោះអ្នកប្រើប្រាស់ និងពាក្យសម្ងាត់។ អ្នកនឹងត្រូវបញ្ចូល MFA (Multi-Factor Authentication, កម្មវិធីផ្ទៀងផ្ទាត់ច្រើនកត្តា)។

23. ចុចប៊ូតុង **<u>BEGIN</u> (ចាប់ផ្តើម)**។




24. វាយបញ្ចូលអាសយដ្ឋានអ៊ីមែលចម្បងរបស់អ្នក រួចចុចប៊ូតុង **<u>NEXT</u> (បន្ទាប់)**។
(អ្នកក៏អាចនឹងវាយបញ្ចូលអាសយដ្ឋានអ៊ីមែលបន្ថែម។)



25. វាយបញ្ចូលលេខទូរសព្ទដែលអាចទទួលសារជាអក្សរបាន រួចចុចប៊ូតុង **<u>NEXT</u> (បន្ទាប់)**។




26. ពិនិត្យមើលព័ត៌មានដែលអ្នកបានវាយបញ្ចូល។ ប្រសិនបើអ្វីគ្រប់យ៉ាងត្រឹមត្រូវ សូមចុចប៊ូតុង **<u>SUBMIT</u>** (**ដាក់បញ្ជូន**)។



## ការប្រើប្រាស់ WSGC My Account (WSGC គណនីរបស់ខ្ញុំ)៖

### សម្រាប់បុគ្គលិកក្នុងបន្ទប់លេងបៀ អ្នកតំណាង ឬអ្នកគ្រប់គ្រងល្បែងស៊ីសង៖

- **Action Center (មជ្ឈមណ្ឌលសកម្មភាព)**គឺជាកន្លែងដែលអ្នកអាចបន្តអាជ្ញាបណ្ណរបស់អ្នក និងផ្លាស់ប្តូរអាសយដ្ឋានរបស់អ្នក។ កន្លែងនោះក៏បង្ហាញកាលបរិច្ឆេទផុតកំណត់អាជ្ញាបណ្ណរបស់អ្នកផងដែរ។

- **អ្នកមិនអាចបន្តអាជ្ញាបណ្ណរបស់អ្នកបានទេ បន្ទាប់ពីអាជ្ញាបណ្ណនោះបានផុតកំណត់។** អ្នកត្រូវតែដាក់បញ្ជូនពាក្យស្នើសុំថ្មី បង់ថ្លៃសេវាអាជ្ញាបណ្ណថ្មី និងដាក់បញ្ជូនកាតស្នាមម្រាមដៃថ្មី។ ទាក់ទងទៅអ្នកឯកទេសផ្នែកផ្តល់អាជ្ញាបណ្ណ ប្រសិនបើអ្នកមិនបានបន្តអាជ្ញាបណ្ណរបស់អ្នកទាន់ពេលវេលា។ ទូរសព្ទទៅ (360) 486-3440 ឬផ្ញើអ៊ីមែលទៅ Licensing@wsgc.wa.gov។

- ផ្នែក **Licensing (ផ្តល់អាជ្ញាបណ្ណ)**គឺជាកន្លែងដែលអ្នកអាចរាយការណ៍ការបំពាន និងស្វែងរកព័ត៌មានទំនាក់ទំនង WSGC បាន។



**<u>សម្រាប់អង្គភាព (អង្គភាពមិនរកប្រាក់ចំណូល និងអាជីវកម្មពាណិជ្ជកម្ម)៖</u>**

- **<u>Action Center</u> (មជ្ឈមណ្ឌលសកម្មភាព)** គឺជាកន្លែងដែលអ្នកអាចបន្តអាជ្ញាបណ្ណរបស់អ្នក បោះពុម្ពច្បាប់ចម្លងអាជ្ញាបណ្ណរបស់អ្នក និងបង្ហោះឯកសារ។ កន្លែងនោះក៏បង្ហាញកាលបរិច្ឆេទផុតកំណត់អាជ្ញាបណ្ណរបស់អ្នកផងដែរ។

- **<u>អ្នកមិនអាចបន្តអាជ្ញាបណ្ណរបស់អ្នកតាមអ៊ីនធឺណិតបានទេ បន្ទាប់ពីអាជ្ញាបណ្ណនោះបានផុតកំណត់។</u>** ទាក់ទងទៅអ្នកឯកទេសផ្នែកផ្តល់អាជ្ញាបណ្ណតាមរយៈ (360) 486-3440 ឬ Licensing@wsgc.wa.gov ប្រសិនបើអាជ្ញាបណ្ណរបស់អ្នកបានផុតកំណត់។ គាត់អាចផ្ញើពាក្យស្នើសុំបន្តឱ្យអ្នកមួយច្បាប់។ (សូមកុំចាប់ផ្តើមដាក់ពាក្យស្នើសុំអាជ្ញាបណ្ណថ្មី។)

- ផ្នែក **<u>Licensing</u> (ផ្តល់អាជ្ញាបណ្ណ)** គឺជាកន្លែងដែលអ្នកអាចរាយការណ៍ការផ្លាស់ប្តូរ និងដាក់ពាក្យស្នើសុំអាជ្ញាបណ្ណបន្ថែម។ អ្នកក៏អាចមើលពាក្យស្នើសុំដែលបានដាក់បញ្ជូនបានផងដែរ។ ប្រសិនបើអ្នកបានផ្តល់អាជ្ញាបណ្ណដល់បុគ្គលិកល្បែងស៊ីសង អ្នកអាចនឹងដាក់បញ្ជូនពាក្យស្នើសុំរបស់ពួកគាត់ និងបំពេញការជូនដំណឹងអំពីការបញ្ឈប់បុគ្គលិក។

- ផ្នែក **<u>Quarterly Reports</u> (របាយការណ៍ប្រចាំត្រីមាស)**គឺជាកន្លែងដែលអ្នកអាចដាក់បញ្ជូនរបាយការណ៍អាជ្ញាបណ្ណប្រចាំត្រីមាស។ ប្រសិនបើអ្នកត្រូវការជំនួយពាក់ព័ន្ធនឹងរបាយការណ៍របស់អ្នក សូមទាក់ទងទៅការិយាល័យអាជីវកម្មរបស់យើងតាមរយៈ FinancialReporting@wsgc.wa.gov ឬ (360) 486-3440 (ជម្រើសទី 2)។



# គន្លឹះសំខាន់ៗ៖

**កម្រងព័ត៌មាន៖**

ចុច Account (គណនី) រួច Profile (កម្រងព័ត៌មាន)។ ផ្នែកនេះបង្ហាញឈ្មោះអ្នកប្រើប្រាស់ និងអាសយដ្ឋានអ៊ីមែលដែលភ្ជាប់ជាមួយនឹងគណនី SAW របស់អ្នក។ ប្រសិនបើព័ត៌មាននេះមិនត្រឹមត្រូវ សូមទាក់ទងទៅផ្នែកផ្តល់សេវារបស់ SAW ដើម្បីទទួលបានជំនួយ។

**ផ្នែកផ្តល់សេវារបស់ SAW ៖ (**855) 928-3241 ឬ (360) 586-1000



**<u>ពាក្យសម្ងាត់៖</u>**
ដើម្បីផ្លាស់ប្តូរពាក្យសម្ងាត់របស់អ្នក សូមចុច Account (គណនី) រួច Password (ពាក្យសម្ងាត់)។ អនុវត្តតាមការណែនាំ ដើម្បីផ្លាស់ប្តូរពាក្យសម្ងាត់របស់អ្នក។ ប្រសិនបើអ្នកមិនអាចផ្លាស់ប្តូរពាក្យសម្ងាត់របស់អ្នកបានទេ សូមទាក់ទងទៅផ្នែកផ្តល់សេវារបស់ SAW ដើម្បីទទួលបានជំនួយ។

**ផ្នែកផ្តល់សេវារបស់ SAW ៖ (**855) 928-3241 ឬ (360) 586-1000

